# ខ្លឹមសារសង្ខេប សេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង (TC) លើសំណើ ឌុច ស្នើសុំដោះលែង E39/5 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩

**១.ពាក្យគន្លឹះ៖** ការបំពានទីតិវិធី, សិទ្ធិទទួលបានសវនាការក្នុងពេលសមស្រប, ការឃុំខ្លួន។

**២. នីតិវិធី៖** ឌុច ត្រូវបានឃាត់ខ្លួនក្នុងឆ្នាំ ១៩៩៩ និងត្រូវបានឃុំ ពន្យាពេលឃុំ ជាបន្តបន្ទាប់ ក្នុងឆ្នាំ ២០០៥, ២០០៧។ សំណុំរឿងគាត់ត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០០៨ ដោយតុលាការយោធាកម្ពុជា។ ការឃុំខ្លួនក្នុងឆ្នាំ ២០០៥ បានផ្អែកទៅលើបទល្មើសថ្មី គឺបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមច្បាប់ស្តីពី អវតក ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០១។ ខែកក្កដា ឆ្នាំ ២០០៧ គាត់ត្រូវបានផ្ទេរមកឃុំខ្លួននៅ អវតក និងពន្យាមួយឆ្នាំក្នុងខែ កក្កដា ឆ្នាំ ២០០៨។ ក្នុងអំឡុងពេលសវនាការ គាត់អះអាងថា ការឃុំខ្លួននៅតុលាការយោធាខុសច្បាប់ ហើយសុំដោះលែងនៅក្រៅឃុំជាមួយលក្ខខណ្ឌ។ ទន្ទឹមនឹងនេះ គាត់ទាមទារឲ្យអង្គជំនុំជម្រះ ផ្តល់ប្រយោជន៍ពីពេលវេលាឃុំខ្លួនកន្លងមក និង ផ្តល់សំណង ដោយកាត់បន្ថយរយៈពេលដាក់ពន្ធនាគារ (ប្រសិនបើមានពិរុទ្ធភាព) ជាថ្នូរនឹងការឃុំខ្លួនខុសច្បាប់។

សហព្រះរាជអាជ្ញា ឆ្លើយតបថា តុលាការយោធា និង អវតក ខុសគ្នា នីតិវិធីនៅតុលាការយោធាមិនត្រូវបានផ្តួចផ្តើមដោយអវតកទេ ការបំពានសិទ្ធិមុន មិនពាក់ព័ន្ធ និងមិនត្រូវដាក់បន្ទុកលើ អវតក ឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណី តាមអះអាងថា អវតក គ្មានកាតព្វកិច្ចពិនិត្យមើលការបំពានសិទ្ធិដោយតុលាការយោធាទេ ហើយ TC ត្រូវតែថ្លឹងថ្លែងនូវផលប្រយោជន៍រវាងសិទ្ធិ ឌុច និង ប្រយោជន៍របស់សហគមន៍អន្តរជាតិ ដែលចង់ឃើញមានយុត្តិធម៌។

## ៣. សំអាងហេតុ និងសេចក្តីសម្រេច

**ក.** TC រកឃើញថា អវតក ឯករាជ្យពីតុលាការជាតិ មានវិធានផ្ទៃក្នុងដោយឡែក និងកម្រិតលើយុត្តាធិការលើបុគ្គលជាក់លាក់ មិនមានចំណងទាក់ទង (line of authority) រវាងតុលាការយោធានិង អវតក។ ទោះបីជាយ៉ាងនេះក្តី តាមទ្រឹស្តីនៃការបំពាននីតិវិធី (abuse of process) ឬការដែលសិទ្ធិរបស់ជនជាប់ចោទ ត្រូវបានបំពានដោយអាជ្ញាធរក្រៅតុលាការ តាមយុត្តិសាស្ត្រអន្តរជាតិ អវតក មានកាតព្វកិច្ចពិនិត្យមើលការបំពាននោះ។ ក្រោយពីពិនិត្យមើលច្បាប់កម្ពុជា អនុញ្ញាតឲ្យឃុំខ្លួនដល់បីឆ្នាំ ហើយការឃុំដាក់ស្តែងរហូតដល់ ៧ឆ្នាំ ដោយតុលាការយោធា (ឆ្នាំ១៩៩៩ ដល់ ២០០៧) នេះ វាជាការខុសច្បាប់

និងបំពានសិទ្ធិទទួលបានសវនាការក្នុងពេលសមស្រប ដោយសារតែ ក្នុងអំឡុងពេលនៃការឃុំខ្លួន មិនមានការស៊ើបអង្កេតហួសចត់ ហើយមូលដ្ឋាននៃការឃុំខ្លួនក៏មិនរឹងមាំផងដែរ។

**ខ**. TC បានរកឃើញថា ការឃុំខ្លួនកន្លងមករបស់ អវតក លើឌុច មានស្ថានភាពឃុំឃាំងល្អ មានមូលដ្ឋានត្រឹមត្រូវ ត្រួតពិនិត្យជាទៀងទាត់ ហើយក្នុងអំឡុងពេលសវនាការនេះ មូលដ្ឋានទាំងនោះ នៅតែមានភាពសមស្រប។

**គ**. TC បានសម្រេចថា ក្នុងករណីដែល ឌុច មានពិរុទ្ធភាព គាត់នឹងទទួលបានការកាត់រយៈពេលជាថ្នូរនឹងការបំពានសិទ្ធិ និង បានផលប្រយោជន៍ពីពេលវេលាដែលគាត់ ត្រូវបានឃុំខ្លួន និង ក្នុងករណី គាត់មិនមានទោស គាត់មានសិទ្ធិប្តឹងទារសំណង នៅមុខអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា (កថាខ័ណ្ឌទី ២៩, ៣៦ និង៣៧)។

**៤. កំណត់សំគាល់ (ខ្លឹមសារល្អ សម្រាប់ដកស្រង់)**

*ទ្រឹស្តីនៃការបំពាននីតិវិធី បង្កើតជាការធានាបន្ថែមនៃសិទ្ធិរបស់ជនជាប់ចោទ និងអាចអនុវត្តក្នុងស្ថានភាពដែលមិនមានសកម្មភាពសហការគ្នា រវាងតុលាការអន្តរជាតិ និងអាជ្ញាធរក្រៅតុលាការ។ ទ្រឹស្តីនេះ ទាមទារឲ្យតុលាការមិនអនុវត្តយុត្តាធិការ ក្នុងករណីជាក់លាក់ ត្រូវបានបកស្រាយចង្អៀត និងកម្រិតលើ ករណីដែលអំពីខុសច្បាប់នោះ ធ្វើឲ្យប៉ះធ្ងន់ធ្ងរដល់ នីតិរដ្ឋ ក្នុងការដាក់បុគ្គលក្នុងសវនាការ* (កថាខ័ណ្ឌទី៣៣) (Prosecutor v. Lubanga, Case No. ICC-01/04-01/06)។

ទស្សនៈទាំងស្រុងសូមមើល៖ Trial Chamber, Decision on Release, E39/5, 15 June 2009